បេឡាជាតិសន្តិសុខសង្គម

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែ

លេខ៖៥

## មាតិកា

### ព្រឹត្តិការណ៍សំខាន់ៗ

➤ ព្រឹត្តិការណ៍សំខាន់ៗ..........................................................២

### ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន

➤ ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.............១៤

### ការស្នើសុំបញ្ជីក្រុមហ៊ុន/សហគ្រាស (Online)

➤ តើលោកអ្នកបានចុះបញ្ជីក្រុមហ៊ុន/សហគ្រាស គ្រឹះស្ថាន អាជីវកម្ម តាមប្រព័ន្ធ Web Base Application ប.ស.ស. ..................១៦

ស្កេនតាមរយៈ QR Code ដើម្បីទាញយកខិត្តប័ណ្ណ វិស័យឯកជន

ស្កេនតាមរយៈ QR Code ដើម្បីទាញយកខិត្តប័ណ្ណ វិស័យសាធារណៈ

Google Drive


## រចនាសម្ព័ន្ធព្រឹត្តិបត្រ ខែតុលា ឆ្នាំ២០២៥

**ឯកឧត្តម ម៉េង ហុង**
**អគ្គនាយក ប.ស.ស.**

**ចាងហ្វាង** ឯកឧត្តមបណ្ឌិត **ហេង សុផាន់ណារិទ្ធ**
**និពន្ធនាយក** លោក **អ៊ុក សំអូន**
**និពន្ធនាយករង** លោកស្រី **ចាន់ ស៊ីណុន**
លោក **ឃុន ទិចិត្រ**
**លេខានិពន្ធ** លោក **យិន គន្ធា**
លោក **យ៉ង់ សុខន**
**ផ្នែកការីកុំព្យូទ័រ** លោក **អ៊ុង ស៊ីខឿ**
អ្នកស្រី **ទិត បញ្ញា**


សូមអានបន្តនៅទំព័រទី២

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រតិភូរាជរដ្ឋាភិបាល អញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យដំណើរការ "ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា"

## កម្រងរូបភាពសកម្មភាព




















**ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យដំណើរការ "ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥។

ថ្នាលគាំពារសង្គមឌីជីថលកម្ពុជា បានបង្ហាញពីការសម្រេចបាននូវបង្គោលចរដ៏សំខាន់ នៃផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ឆ្នាំ២០២៤-២០២៨ ក៏ដូចជានឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពបន្ថែមទៀត សម្រាប់ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ របស់រាជរដ្ឋាភិបាល។

សូមបញ្ជាក់ថា៖ពិធីប្រកាសដាក់ឱ្យដំណើរការខាងលើប្រព្រឹត្តទៅនៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិប្រមាណជាង ១០០០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ដឹកនាំកិច្ចប្រជុំប្រចាំអឌ្ឍមាសទី១ ដើម្បីតាមដានលទ្ធផលការងារសម្រេចបាន និងពង្រឹងគុណភាពនៃផ្តល់សេវា ប.ស.ស. ជូនសមាជិក

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំកិច្ចប្រជុំប្រចាំអឌ្ឍមាសទី១ ដើម្បីពិនិត្យ និងតាមដានការអនុវត្តការងារពាក់ព័ន្ធនឹងការផ្តល់សេវារបស់ ប.ស.ស. ដោយមានការចូលរួមពីសំណាក់ឯកឧត្តមអគ្គនាយករង លោក លោកស្រី ប្រធាន អនុប្រធាននាយកដ្ឋាន អង្គភាព និងមន្ត្រីជំនាញពាក់ព័ន្ធ សរុបប្រមាណជា ៨០រូប ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំខាងលើ មានគោលបំណងសំខាន់ដើម្បីពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពការងារដែលសម្រេចបាននាពេលកន្លងមក ព្រមទាំងពិនិត្យលើបញ្ហាប្រឈមដែលនៅសេសសល់ និងដាក់ចេញនូវទិសដៅអនុវត្តការងារអាទិភាពបន្តទៀត ដើម្បីធានាថា ការផ្តល់សេវារបស់ ប.ស.ស. ជូនដល់សមាជិករបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ច្បាស់លាស់ និងទាន់ពេលវេលា។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ក៏បានផ្តល់អនុសាសន៍ណែនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញទាំងអស់ឱ្យបន្តពង្រឹងស្មារតីទទួលខុសត្រូវ និងសាមគ្គីភាពផ្ទៃក្នុងឱ្យបានរឹងមាំ ជាពិសេសត្រូវពង្រឹងយន្តការផ្តល់សេវាឱ្យកាន់តែរហ័ស ទាន់ចិត្ត និងតម្លាភាព ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ទទួលជួបគណៈប្រតិភូមូលនិធិកណ្តាលសម្រាប់ជួយគ្នាទៅវិញទៅមកនៅក្នុងវិស័យកសិកម្ម (CCMSA) នៃប្រទេសបារាំង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើប្រព័ន្ធសន្តិសុខសង្គម

## កម្រងរូបភាពសកម្មភាព



នារសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុញ្ញាតឱ្យគណៈប្រតិភូនៃមូលនិធិកណ្តាលសម្រាប់ជួយគ្នាទៅវិញទៅមកនៅក្នុងវិស័យកសិកម្ម (CCMSA) នៃប្រទេសបារាំង ដឹកនាំដោយលោក Pierre Pigeon អគ្គនាយកប្រចាំតំបន់ Poitou នៃមូលនិធិ CCMSA ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្នាក់ការកណ្តាល ប.ស.ស. ក្រោមក្របខ័ណ្ឌគម្រោងស្តីពី ការពង្រឹងការបន្សាំរបបធានារ៉ាប់រងសង្គម (SASI)។

ក្នុងជំនួបដ៏កក់ក្តៅ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសម្តែងការស្វាគមន៍ និងអបអរសាទរចំពោះភាពជោគជ័យនៃការអនុវត្តគម្រោង រវាងកិច្ចសហប្រតិបត្តិការរបស់ ប.ស.ស. ជាមួយនឹងអង្គការហ្គ្រេត (GRET) កន្លងមក។ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសម្តែងនូវជំនឿយ៉ាងមុតមាំថា ភាគីទាំងពីរនឹងបន្តកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធថែមទៀត ដើម្បីការអនុវត្តគម្រោង SASI នេះ អាចពង្រីកការធានារ៉ាប់រងសុខភាពសង្គមដល់ប្រជាជននៅតាមជនបទក្នុងប្រទេសកម្ពុជា ពិសេសលើវិស័យកសិកម្ម ដើម្បីដោះស្រាយបញ្ហាភាពងាយរងគ្រោះរបស់ប្រជាជននៅតាមជនបទចំពោះហានិភ័យផ្សេងៗ។

ក្នុងឱកាសមកបំពេញទស្សនកិច្ចជាលើកទី២ នេះ គណៈប្រតិភូ CCMSA បានធ្វើសេចក្តីរាយការណ៍សង្ខេបអំពីគោលបំណងសំខាន់នៃការមកបំពេញទស្សនកិច្ចនៅ ប.ស.ស. កម្ពុជា ដោយបង្ហាញពីការប្តេជ្ញាចិត្តក្នុងការបង្កើនកិច្ចសហប្រតិបត្តិការនានាជាមួយ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ជាពិសេសក្នុងវិស័យកសិកម្ម ដែលនេះជាសញ្ញាបញ្ជាក់ពីការពង្រឹងភាពជាដៃគូដ៏រឹងមាំ ដើម្បីអភិវឌ្ឍវិស័យសន្តិសុខសង្គមនៅកម្ពុជាឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

សូមរំលឹកផងដែរថា គណៈប្រតិភូ CCMSA ធ្លាប់បានមកបំពេញទស្សនកិច្ចនៅកម្ពុជាកាលពីឆ្នាំ២០២៤ រួចមកហើយ ដើម្បីសិក្សាស្វែងយល់ពីវឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមរបស់ ប.ស.ស. កម្ពុជា និងដើម្បីពិនិត្យពិភាក្សាលើវឌ្ឍនភាពនៃគម្រោង SASI ព្រមទាំងចែករំលែកបទពិសោធន៍ដែលពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គមរបស់ប្រទេសបារាំង ដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកជំនាញ ប.ស.ស. ផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. អញ្ជើញជាអធិបតី បើកវគ្គបណ្តុះបណ្តាលស្តីពី ពិធីការ និងបដិសណ្ឋារកិច្ច និងការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន ដើម្បីបង្កើនសមត្ថភាពមន្ត្រី និងបុគ្គលិកក្រោមឱវាទ

## កម្រងរូបភាពសកម្មភាព











នាព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីភាពបើកវគ្គបណ្តុះបណ្តាលស្តីពី ពិធីការ និងបដិសណ្ឋារកិច្ច និងការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន ជូនដល់ថ្នាក់ដឹកនាំសាខា ប.ស.ស. ខេត្ត-ខណ្ឌ មន្ត្រី និងបុគ្គលិកក្រោមឱវាទបេឡាជាតិសន្តិសុខសង្គម សរុបប្រមាណជា ៩០រូប នៅសាលប្រជុំករុណា ស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

មានប្រសាសន៍ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានថ្លែងថា វគ្គបណ្តុះបណ្តាលនាឱកាសនេះ ជាតម្រូវការចាំបាច់សម្រាប់ប្រសិទ្ធភាពប្រតិបត្តិការនៃស្ថាប័ន និងដើម្បីពង្រឹងសមត្ថភាពរបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកក្រោមឱវាទ ប.ស.ស. ដើម្បីអាចឈ្វេងយល់គ្រប់ជ្រុងជ្រោយទៅលើការងារពិធីការ និងការទទួលបដិសណ្ឋារកិច្ច សម្រាប់កម្មវិធី សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានបន្ថែមថា វគ្គបណ្តុះបណ្តាលពិធីការ និងបដិសណ្ឋារកិច្ចនាព្រឹកនេះ ជាលើកទី២ហើយ ដែលបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស ដែលទាមទារឱ្យថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស. យកចិត្តទុកដាក់ឱ្យបានខ្ពស់ ដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីរបៀបរបបនៃការរៀបចំព្រឹត្តិការណ៍ ការរៀបចំដំណើរទស្សនកិច្ចផ្លូវការ ការរៀបចំកិច្ចប្រជុំ កម្មវិធីផ្លូវការនានាផងដែរ។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមទាំងអស់ នឹងខិតខំសិក្សារៀនសូត្រ ក្រេបចំណេះដឹងថ្មី សម្រាប់បំពេញបន្ថែមនូវចំណុចខ្វះខាតរបស់ខ្លួនប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីយកមកអនុវត្តក្នុងអង្គភាពរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើនេះ ប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី ២២-២៤ ខែតុលា ឆ្នាំ២០២៥ និងមានការធ្វើបទបង្ហាញដោយ **ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ ឥន សុផល** គ្រូឧទ្ទេសមកពីវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគ្រូឧទ្ទេសដែលជាថ្នាក់ដឹកនាំ ក្នុង ប.ស.ស. ធ្វើបទបង្ហាញអំពីការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង ប្រតិភូរាជរដ្ឋាភិបាល អញ្ជើញថ្លែងរបាយការណ៍ស្វាគមន៍ក្នុងពិធីបើក "សិក្ខាសាលាពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូលលើម៉ូដែលវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកថែទាំសុខភាព"

## កម្រងរូបភាពសកម្មភាព











នាព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញថ្លែងរបាយការណ៍ស្វាគមន៍ក្នុងពិធីបើក "សិក្ខាសាលាពិគ្រោះយោបល់ដើម្បីប្រមូលធាតុចូលលើម៉ូដែលវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកថែទាំសុខភាព" ក្រោមអធិបតីភាព **ឯកឧត្តម គួច សុមាន** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសង្កត់ធ្ងន់ថា អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម ប.ស.ស. ត្រូវធ្វើការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុរៀងរាល់១ឆ្នាំម្តង សម្រាប់ផ្នែកថែទាំសុខភាព ៣ឆ្នាំម្តងសម្រាប់ផ្នែកហានិភ័យការងារ និង៥ឆ្នាំម្តងសម្រាប់ផ្នែកប្រាក់សោធន ដូចនេះ ប.ស.ស. ចាំបាច់ណាស់ត្រូវមានម៉ូដែលវាយតម្លៃហានិភ័យហិរញ្ញវត្ថុតាមផ្នែកនីមួយៗរបស់ខ្លួន ដើម្បីធានាបាននូវនិរន្តរភាពហិរញ្ញវត្ថុ សម្រាប់ការផ្តល់សេវាជូនសមាជិក ប.ស.ស. ។

ក្នុងរបាយការណ៍ស្វាគមន៍នោះដែរ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានគូសបញ្ជាក់ពី ម៉ូដែលវាយតម្លៃហានិភ័យហិរញ្ញវត្ថុក្នុងការជួយគណនាទៅលើស្ថិតិ សមាជិក ប.ស.ស. ដែលបានបង់ភាគទាន, កំណត់ប្រាក់ឈ្នួលជាប់ភាគទាន, ប្រាក់ចំណូលភាគទាន, ចំនួនទឹកប្រាក់ចំណាយរំពឹងទុកតាវកាលិកព្យាបាល និងថៃទាំវេជ្ជសាស្ត្រតាមប្រភេទសេវា និងតាវកាលិកសាច់ប្រាក់តាមប្រភេទ ដើម្បីអាចព្យាករណ៍ពីតម្រូវការចំណាយតាវកាលិក និងចំណាយប្រតិបត្តិការនាពេលអនាគត ដើម្បីអាចធ្វើកំណែទម្រង់បានទាន់ពេលវេលា។

ជាមួយគ្នានោះដែរ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានអំពាវនាវដល់អ្នកចូលរួមសិក្ខាសាលា ដែលមានឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ និងសមាជិក សមាជិកា ទាំងអស់ជួយផ្តល់ធាតុចូលប្រកបដោយការស្ថាបនា ដើម្បីឱ្យម៉ូដែលវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកថែទាំសុខភាពនេះ កាន់តែមានភាពរឹងមាំ ជាក់លាក់ និងអាចឆ្លើយតបទៅនឹងបរិបទបច្ចុប្បន្ន និងអនាគត នៃការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង អញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុង ប.ស.ស. ប្រចាំខែតុលា ឆ្នាំ២០២៥ ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ របស់អង្គភាពក្រោមឱវាទរបស់បេឡាជាតិសន្តិសុខសង្គម

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុង ប.ស.ស.ប្រចាំខែតុលា ឆ្នាំ២០២៥ ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ និងត្រួតពិនិត្យលទ្ធផលការងារសម្រេចបាន និងទិសដៅអនុវត្តបន្ត ព្រមទាំងពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាព។

ក្នុងឱកាសនោះដែរ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានជំរុញដល់ថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទទាំងអស់ ត្រូវបង្កើនកិច្ចសហការរវាងគ្នា ដោយមានភាពយោគយល់អធ្យាស្រ័យគ្នា ពិសេសត្រូវមានសាមគ្គីភាពផ្ទៃក្នុងជាធ្លុងមួយដើម្បីដើរលើផ្លូវរួមគ្នា ក្នុងការអនុវត្តការងារឱ្យបានល្អប្រសើរ និងដោះស្រាយបញ្ហាប្រឈមឱ្យបានឆាប់រហ័ស ជាពិសេសការពង្រឹងគោរពវិន័យក្នុងអង្គភាពឱ្យហ្មត់ចត់ តឹងរ៉ឹង និងខិតខំអនុវត្តទិសដៅការងារបន្ត និងដោះស្រាយការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយការទំនួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់ ជាមួយនឹងភាពទន់ភ្លន់ ម៉ឺងមាត់ ដើម្បីជំរុញយន្តការបម្រើសេវាសាធារណៈជូនសមាជិក ឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលខ្ពស់។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំនេះ ប្រព្រឹត្តទៅនៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមដោយផ្ទាល់ពីសំណាក់ឯកឧត្តមអគ្គនាយករង លោក/លោកស្រីប្រធាននាយកដ្ឋាន/អង្គភាព លោក/លោកស្រីអនុប្រធាននាយកដ្ឋាន និងចូលរួមតាមប្រព័ន្ធ Zoom ពីសំណាក់លោក/លោកស្រីប្រធាន និងអនុប្រធានសាខា ប.ស.ស. ខេត្ត-ខណ្ឌ ចំនួន១៤៧រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អញ្ជើញដឹកនាំកិច្ចប្រជុំ គណៈកម្មការសម្របសម្រួលគម្រោង " ការពង្រឹងការបន្សាំរបបធានារ៉ាប់រងសង្គម ( SASI )"

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានគណៈកម្មការសម្របសម្រួលគម្រោង SASI តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានអញ្ជើញដឹកនំកិច្ចប្រជុំគណៈកម្មការសម្របសម្រួលគម្រោង "ការពង្រឹងការបន្សាំរបបធានារ៉ាប់រងសង្គម (SASI)" ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្ដាល ប.ស.ស. ដោយមានវត្តមានអញ្ជើញចូលរួមពីលោក លោកស្រី អនុប្រធាន សមាជិក សមាជិកា នៃគណៈកម្មការសម្របសម្រួលគម្រោង តំណាងអង្គការហ្គ្រេត (GRET) តំណាងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) និងជំនាញការគម្រោង សរុបប្រមាណជា ៤០រូប។

កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យ ពិភាក្សា ប្រមូលធាតុចូល មតិយោបល់ និងអនុសាសន៍លើសេចក្ដីព្រាងសំណើជាយុទ្ធសាស្ត្រសម្រាប់ការពង្រីកការគ្របដណ្ដប់របបសន្តិសុខសង្គមដល់ប្រជាជននៅតាមទីជនបទ ដែលបន្សាំនឹងបម្រែបម្រួលអាកាសធាតុ។

គួររំលឹកថា គម្រោងស្ដីពី "ការពង្រឹងការបន្សាំរបបធានារ៉ាប់រងសង្គម (SASI)" គឺជាកិច្ចសហការអនុវត្តរវាង ប.ស.ស. នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងអង្គការហ្គ្រេត (GRET) ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) ចាប់ពីឆ្នាំ២០២៣ មកម្លេះ ដែលមានគោលបំណងរួម គឺដើម្បីសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ការអនុវត្តរបបសន្តិសុខសង្គមដែលបន្សាំទៅនឹងកម្លាំងពលកម្មតាមទីជនបទ ឆ្ពោះទៅរកការពង្រីកការគ្របដណ្ដប់របបសន្តិសុខសង្គមលើវិស័យកសិកម្មនៅក្នុងការបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កោះកុង ជាខេត្តដែលមានរថយន្តដឹកជញ្ជូនកម្មករនិយោជិត មានលក្ខណៈបច្ចេកទេសល្អ មានផាសុកភាព និងសុវត្ថិភាព

## កម្រងរូបភាពសកម្មភាព




នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាសហាធិបតីក្នុងពិធីបើកកម្មវិធីអប់រំផ្សព្វផ្សាយ "ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពក្នុងការធ្វើដំណើររបស់កម្មករនិយោជិតជូនអ្នកបើកបររថយន្តដឹកជញ្ជូនកម្មករនិយោជិត និងកម្មករនិយោជិត" នៅរោងចក្រ KKN APPAREL CO., LTD ដែលមានអ្នកចូលរួមប្រមាណជាង ៤៥០រូប។

ថ្លែងបើកពិធីផ្សព្វផ្សាយ **ឯកឧត្តមបណ្ឌិតប្រធានក្រុមការងារ** បានឱ្យដឹងថា ខេត្តកោះកុង ជាខេត្តមួយដែលមានរថយន្តដឹកជញ្ជូនកម្មករនិយោជិត មានលក្ខណៈបច្ចេកទេសល្អ មានផាសុកភាព និងសុវត្ថិភាព ដែលអាចចាត់ទុកជាខេត្តគំរូ ក្នុងការជំរុញការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព យ៉ាងយូរត្រឹមឆ្នាំ២០២៧ ក្នុងគោលបំណងកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ក៏ដូចជារក្សាបាននូវប្រាក់ចំណូល លើកកម្ពស់សុខុមាលភាព សុវត្ថិភាពការងារ និងសុវត្ថិភាពក្នុងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត។

**ឯកឧត្តមបណ្ឌិតប្រធានក្រុមការងារ** បានបន្ថែមថា បើទោះបីជាក្នុងខេត្តនេះ ករណីគ្រោះថ្នាក់ចរាចរណ៍លើរថយន្តដឹកជញ្ជូនកម្មករនិយោជិតពុំសូវកើតមានក៏ពិតមែន ប៉ុន្តែការចុះអប់រំផ្សព្វផ្សាយនៅតែជាយន្តការអនុវត្តជាប្រចាំ របស់ក្រុមការងារ ស.ផ.ក ដើម្បីរួមចំណែកក្នុងការបញ្ជ្រាបការយល់ដឹងអំពីច្បាប់ចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពក្នុងការធ្វើដំណើរ និងទាមទារឱ្យមានការចូលរួមផ្ទាល់ពីសាមីខ្លួន និងគ្រប់ភាគីពាក់ព័ន្ធ ក្នុងការអនុវត្តច្បាប់ និងគោរពសិទ្ធិគ្នាទៅវិញទៅមកនៅពេលបើកបរ ដើម្បីអាចចៀសវាងពីគ្រោះថ្នាក់នៅលើដងផ្លូវ។

មានប្រសាសន៍ក្នុងពិធីនេះផងដែរ **ឯកឧត្តម ហាក់ ឡេង** អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង បានសម្តែងនូវការអរគុណ និងកោតសរសើរចំពោះស្ថាប័នពាក់ព័ន្ធនានា ពិសេស ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកន្លងមកតែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការចុះអប់រំផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកជូនដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិត តាមគ្រប់រូបភាព ហើយជាពិសេសម្ចាស់រោងចក្រ សហគ្រាស ទាំងអស់ ក្នុងទឹកដីនៃខេត្តកោះកុង ត្រូវចូលរួមជំរុញ លើកទឹកចិត្ត និងផ្តល់ពេលវេលាគ្រប់គ្រាន់ដល់កម្មករនិយោជិត នៅតាមរោងចក្រ សហគ្រាស របស់ខ្លួន ឱ្យចូលរួមកម្មវិធីអប់រំផ្សព្វផ្សាយនានាពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពក្នុងពេលធ្វើដំណើរ ឱ្យបានកាន់តែច្រើនបន្ថែមទៀត ដើម្បីឱ្យពួកគាត់បានយល់ដឹង និងចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។

ក្នុងឱកាសជាមួយគ្នានេះ **ឧត្តមសេនីយ៍ឯក ទូច សុភា** អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏បានធ្វើការអំពាវនាវដល់កម្មករនិយោជិតទាំងអស់ មេត្តាបង្កើនការប្រុងប្រយ័ត្នឱ្យបានខ្ពស់ក្នុងការធ្វើដំណើរ ចំពោះអ្នកធ្វើដំណើរដោយមធ្យោបាយផ្ទាល់ខ្លួន ហើយអ្នកបើកបររថយន្តដឹកកម្មករនិយោជិតទាំងអស់ ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ និងយកចិត្តទុកដាក់រាល់ពេលបើកបរ ដោយត្រូវចូលរួមអនុវត្ត និងគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឱ្យបានខ្ជាប់ខ្ជួន ចៀសវាងបង្កជាហានិភ័យគ្រោះថ្នាក់ណាមួយកើតឡើង ព្រោះកម្មករនិយោជិតរាប់សិបនាក់ បានផ្ញើជីវិតនៅលើរថយន្តរបស់អ្នក៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ ដឹកនាំក្រុមការងារបច្ចេកទេស ចូលរួមក្នុងជំនួបពិភាក្សាការងារជាមួយគណៈកម្មការទី៨ នៃរដ្ឋសភា

## កម្រងរូបភាពសកម្មភាព



នារសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំក្រុមការងារបច្ចេកទេស ចូលរួមក្នុងជំនួបពិភាក្សាការងាររវាងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃរដ្ឋសភាជាមួយតំណាងក្រសួងសុខាភិបាល តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) និងក្រុមហ៊ុនផលិតវីដេអូ ដើម្បីរៀបចំផលិតវីដេអូអប់រំខ្លីៗ ទាក់ទងសុខភាពសាធារណៈ និងសុខុមាលភាពកម្មករ និយោជិត ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈុន ស៊ីរុន** សមាជិកគណៈកម្មការទី៨នៃរដ្ឋសភា។

កិច្ចប្រជុំពិភាក្សានេះធ្វើឡើងក្នុងគោលបំណងពិនិត្យមើល និងផ្តល់ធាតុចូលបន្ថែមក្នុងការរៀបចំសាច់រឿងវីដេអូអប់រំ ដែលគ្រោងផលិតនាពេលខាងមុខ ធានាឱ្យបានខ្លឹមសារអប់រំមានគុណភាព និងស្របតាមលក្ខណៈបច្ចេកទេស។

សូមបញ្ជាក់ថា កិច្ចប្រជុំខាងលើ ប្រព្រឹត្តទៅនៅសាលប្រជុំគណៈកម្មការទី៨ នៅវិមានរដ្ឋសភា ដោយមានអ្នកចូលរួមប្រមាណជា ២០រូប។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អញ្ជើញជាអធិបតីបើកទិវាអន្តរជាតិស្ត្រីជនបទ គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាន

## កម្រងរូបភាពសកម្មភាព











នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីបើកទិវាអន្តរជាតិស្ត្រីជនបទ គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាននៅកម្ពុជា។

មានប្រសាសន៍ក្នុងពិធីបើកទិវាអន្តរជាតិស្ត្រីជនបទ **ឯកឧត្តមបណ្ឌិត** បានថ្លែងថា ស្ត្រីត្រូវបានទទួលស្គាល់ថា មានតួនាទីដ៏សំខាន់ក្នុងការរួមចំណែកលើកកម្ពស់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ក្រោមរូបភាពកែលម្អសន្តិសុខស្បៀង លុបបំបាត់ភាពក្រីក្រនៅតាមជនបទ ពង្រឹងភាពអង់អាច និងភាពជាអ្នកដឹកនាំរបស់ស្ត្រីតាមជនបទនៅកម្ពុជា។ លើសពីនេះ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់អត្ថប្រយោជន៍របបសន្តិសុខសង្គមទៅសមាជិក ដែលជាស្ត្រីដូចជាផ្តល់ជូនប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម២ឆ្នាំ និងប្រាក់បំណាច់ប្រចាំថ្ងៃ៧០%រួមទាំងការផ្តល់ជូនសេវាព្យាបាលដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលដៃគូ ប.ស.ស. នៅពេលជួបគ្រោះថ្នាក់ និងមានបញ្ហាសុខភាពផងដែរ។

**ឯកឧត្តមបណ្ឌិត** ថ្លែងបន្តថា នាពេលកន្លងមក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអុកស្វាម (OXFAM) បានសហការរៀបចំវគ្គបណ្តុះបណ្តាល និងវេទិកាសាធារណៈប្រចាំឆ្នាំជាច្រើនលើករួចមកហើយ ដើម្បីចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងមតិយោបល់ល្អៗ ក៏ដូចជាដំណោះស្រាយលើបញ្ហាប្រឈមនានា និងបង្កើនការផ្សព្វផ្សាយគោលនយោបាយគាំពារសង្គមឱ្យបានកាន់តែទូលំទូលាយដល់គ្រប់មជ្ឈដ្ឋាន នៅក្នុងប្រទេសកម្ពុជា។

សូមបញ្ជាក់ថា៖ ទិវាខាងលើប្រព្រឹត្តទៅនៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប ដោយមានវត្តមានអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ ប.ស.ស. តំណាងអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋបាលខេត្តសៀមរាប អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម មូលនិធិជាតិជំនួយសង្គម អង្គការអុកស្វាមអុកស្វាម (OXFAM) និងតំណាងក្រសួង ស្ថាប័នជាតិ-អន្តរជាតិ សរុបប្រមាណជាង ៣៥០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បើកពិធីផ្សព្វផ្សាយដាក់ឱ្យដំណើរការជាផ្លូវការ កម្មវិធីទូរសព្ទដៃ NSSF Enterprise APP ដើម្បីផ្តល់ភាពងាយស្រួលដល់ម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ ក្នុងការចុះបញ្ជី និងបង់ភាគទានមក ប.ស.ស.

## កម្រងរូបភាពសកម្មភាព











នាព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតី បើកពិធីផ្សព្វផ្សាយស្តីពី ការដាក់ឱ្យដំណើរការ និងណែនាំពីនីតិវិធីនៃការចុះបញ្ជី និងបង់ភាគទានតាមរយៈ កម្មវិធីទូរសព្ទដៃ NSSF Enterprise APP ជូនដល់តំណាងម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ សរុបប្រមាណ ៤០០រូប នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

មានប្រសាសន៍បើកពិធីផ្សព្វផ្សាយ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានថ្លែងឡើងថា កម្មវិធីទូរសព្ទដៃ NSSF Enterprise APP ជាសមិទ្ធផលប្រព័ន្ធបច្ចេកវិទ្យាឌីជីថលថ្មីរបស់ ប.ស.ស. ដែលមានមុខងារសំខាន់ៗ អាចជួយសម្រួលដល់ការអនុវត្តការងារប្រចាំថ្ងៃរបស់ម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ ក្នុងការចុះបញ្ជីកម្មករនិយោជិតថ្មី ពិនិត្យព័ត៌មានសហគ្រាស ក្រុមហ៊ុន រោងចក្រ និងសមាជិក ការតាមដានប្រវត្តិបង់ភាគទាន និងពិនិត្យប្រតិបត្តិការបញ្ចូលប្រាក់តម្កល់ រួមទាំងការទូទាត់ផ្សេងៗ ដោយគ្រាន់តែលោកអ្នកមានទូរសព្ទក្នុងដៃ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា តំណាងម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ ទាំងអស់ ដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយពេញមួយព្រឹកនេះ និងទទួលបានចំណេះដឹងអំពីនីតិវិធី និងអត្ថប្រយោជន៍តាមរយៈកម្មវិធីថ្មីនេះ និងទាញយកកម្មវិធី NSSF Enterprise APP ប្រើប្រាស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងការងារពាក់ព័ន្ធនិង ប.ស.ស. និងរួមចំណែកក្នុងការបន្តលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ប.ស.ស. ដោយផ្តោតលើអាទិភាពគន្លឹះលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។

សូមបញ្ជាក់ថា៖ មុនពេលដំណើរការកម្មវិធី NSSF Enterprise APP នេះ កន្លងមក ប.ស.ស. បានអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាឌីជីថលដែលរួមមាន៖ ប្រព័ន្ធ Web base application, NSSF member app ដែលអនុញ្ញាតឱ្យសមាជិក ប.ស.ស និងម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ ពិនិត្យព័ត៌មាន តាមដានប្រវត្តិ ប្រតិបត្តិការផ្សេងៗទាក់ទងនិង ប.ស.ស. ផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# វគ្គបណ្តុះបណ្តាលស្តីពី "ពិធីការ និងបដិសណ្ឋារកិច្ច និងការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន" បានបិទបញ្ចប់ដោយជោគជ័យ

## កម្រងរូបភាពសកម្មភាព



វគ្គបណ្តុះបណ្តាលស្តីពី "ពិធីការ និងបដិសណ្ឋារកិច្ច និងការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន" ដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២២-២៤ ខែតុលា ឆ្នាំ២០២៥ បានបិទបញ្ចប់ដោយជោគជ័យ។

ពិធីបិទវគ្គបណ្តុះបណ្តាល ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ប៉ែន នរៈឧុធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក សរុបប្រមាណជា ៩០រូប នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

ក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានលើកឡើងថា វគ្គបណ្តុះបណ្តាលស្តីពី ពិធីការ និងបដិសណ្ឋារកិច្ចនាពេលនេះ ពិតជាសំខាន់ណាស់ក្នុងការយល់ដឹងស៊ីជម្រៅអំពីក្បួនច្បាប់ នីតិវិធីនៃការរៀបចំពិធីផ្លូវការ និងការទទួលភ្ញៀវជាតិ អន្តរជាតិ ឱ្យមានភាពត្រឹមត្រូវ សមរម្យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ដោយឡែកការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន ក៏ជាចំណេះដឹងដ៏សំខាន់ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងការយល់ដឹងច្បាស់លាស់អំពីហានិភ័យ និងវិធានការការពារចាំបាច់នានា ដើម្បីធានាសុវត្ថិភាពទិន្នន័យ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ន។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** បានថ្លែងអំណរគុណចំពោះគ្រូឧទ្ទេស និងសិក្ខាកាមទាំងអស់ ដែលបានខិតខំយកចិត្តទុកដាក់សិក្សា និងផ្លាស់ប្តូរបទពិសោធន៍ពេញមួយវគ្គសិក្សា ដើម្បីរួមចំណែកក្នុងការបំពេញភារកិច្ចបម្រើសេវាសាធារណៈ ជូនដល់បងប្អូនកម្មករនិយោជិត ប្រកបដោយប្រសិទ្ធភាព៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ ដឹកនាំមន្ត្រីជំនាញប្រជុំពិភាក្សាជាមួយលោកស្រី Kristina Knispel នាយកកម្មវិធី នៃកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ប្រចាំនៅកម្ពុជា ស្ដីពី "ការគាំទ្រសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់ ប.ស.ស."

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានដឹកនាំមន្ត្រីជំនាញ ប.ស.ស. ប្រជុំពិភាក្សាជាមួយ **លោកស្រី** Kristina Knispel នាយកកម្មវិធី នៃកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ប្រចាំនៅកម្ពុជា ស្ដីពី "ការគាំទ្រសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់ ប.ស.ស." ។

កិច្ចប្រជុំពិភាក្សានេះ ផ្ដោតសំខាន់លើការពិនិត្យឈ្វេងយល់អំពីមុខងារ និងថ្នាល នៃប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលមានស្រាប់របស់ ប.ស.ស. ដើម្បីរៀបចំពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ និងឈានទៅរកការធ្វើបរិវត្តកម្មប្រព័ន្ធ ក្នុងគោលដៅចម្បងលើកកម្ពស់ការផ្ដល់សេវារបបសន្តិសុខសង្គមដល់សមាជិក ប.ស.ស. ទាំងអស់ ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងប្រកបដោយបរិយាបន្ន ដែលស្របតាមនិន្នាការសកល និងទិសដៅអភិវឌ្ឍន៍ជាតិរដ្ឋាភិបាលឌីជីថលកម្ពុជា។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមអគ្គនាយករង** ក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ដែលបានបន្តគាំទ្រយ៉ាងសកម្មដល់ ប.ស.ស. ជាពិសេសការគាំទ្រនានាដល់ការរីកចម្រើននៃប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា។

សូមបញ្ជាក់ កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅទីស្នាក់ការកណ្ដាល ប.ស.ស. ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃ ប.ស.ស. និងសហការី នៃកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ចំនួន១០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.






facebook

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
☛សមាជិក ប.ស.ស. ជាគ្រូបង្រៀនម្នាក់ នៅខេត្តកំពង់ធំ ទទួលបានការព្យាបាល ដោយសេវាឥតគិតថ្លៃតាមរយៈ ប.ស.ស.




facebook

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
☛ដំណឹងល្អ! សម្រាប់បងប្អូនស្ត្រី ពិសេសសមាជិក ប.ស.ស. អាចមកទទួលការពិនិត្យស្វែងរកជំងឺមហារីកមាត់ស្បូន បានដោយមិនគិតថ្លៃ នៅមន្ទីរពេទ្យ ហ្លួង ម៉ែ

facebook

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
☛សម្រាប់សមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ទាំងអស់ អាចបង់ភាគទានមក ប.ស.ស. ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ នៃរៀងរាល់ខែ




© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# តើលោកអ្នកបានចុះបញ្ជីក្រុមហ៊ុន/សហគ្រាស គ្រឹះស្ថាន អាជីវកម្ម តាមប្រព័ន្ធ Web Base Application ប.ស.ស. ហើយឬនៅ?




ឥលូវនេះ លោកអ្នកអាចចុះបញ្ជីក្រុមហ៊ុន/សហគ្រាស គ្រឹះស្ថាន បានដោយខ្លួនឯង ដោយត្រឹមរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ ដោយប្រើប្រាស់ប្រព័ន្ធចុះបញ្ជី និងបង់ភាគទាន ប.ស.ស. តាមថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់បេឡាជាតិសន្តិសុខសង្គម។
ងាយស្រួល ចំណេញពេលវេលា និងថវិកា!

## របៀបបង្កើត គណនី ដើម្បីចុះបញ្ជី តាមប្រព័ន្ធ Web Base Application




១. ចូលទៅតំណ enterprise.nssf.gov.kh ឬ ស្កែនតាមរយៈ QR Code ខាងក្រោម រួចចុចលើពាក្យ "ចុះឈ្មោះ"

២. បំពេញព័ត៌មាននៅក្នុងប្រអប់នីមួយៗឱ្យបានត្រឹមត្រូវ និងភ្ជាប់ឯកសារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

៣. បន្ទាប់មកចុចលើប៊ូតុង "ចុះឈ្មោះ"




៤. សូមធ្វើការ Login ចូលទៅក្នុង Email រួចចុចលើប៊ូតុងនេះ ដើម្បីបញ្ជាក់ពីការបង្កើតគណនីរបស់អ្នកបានជោគជ័យ










YouTube

**សូមស្កែន ដើម្បីទស្សនាវីដេអូណែនាំអំពី**
**របៀបបង្កើត គណនី ដើម្បីចុះបញ្ជី**
**តាមប្រព័ន្ធ Web Base Application**

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# របៀបចុះបញ្ជីក្រុមហ៊ុន/សហគ្រាស គ្រឹះស្ថាន អាជីវកម្ម
# តាមប្រព័ន្ធ Web Base Application




៦ ចុច "ចុះបញ្ជី"



៦.១ ជ្រើសរើសប្រភេទក្រុមហ៊ុន ដែលសមស្របទៅនឹងការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ពន្ធដារ ឬស្ថាប័នដទៃ ទៀត

ចុច "បន្ទាប់"



ពិនិត្យព័ត៌មាន និងឯកសារឡើងវិញ

ចុច "ដាក់ស្នើ"

សូមស្កែន ដើម្បីទស្សនាវីដេអូណែនាំអំពី ការប្រើប្រាស់របៀបចុះបញ្ជី តាមប្រព័ន្ធ Web Base Application

YouTube




ការដាក់ស្នើរបស់អ្នកទទួលបានជោគជ័យ សូមរង់ចាំការពិនិត្យសំណើ និងឯកភាព ពីមន្ត្រីប.ស.ស.

៦.២




៦.៣ បន្ទាប់ពីមន្ត្រីប.ស.ស. បានឯកភាពរួច សហគ្រាសរបស់អ្នកត្រូវបានចុះបញ្ជីក្នុង ប.ស.ស. ដោយស្វ័យប្រវត្ត

ពិនិត្យមើល ព័ត៌មានលំអិត

លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន

# របៀបចុះបញ្ជីសមាជិក ប.ស.ស.
# តាមប្រព័ន្ធ Web Base Application




© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# របៀបចុះបញ្ជីសមាជិក ប.ស.ស.
# តាមប្រព័ន្ធ Web Base Application (ត)

លទ្ធផលការស្វែងរកតាមរយៈរូបថត និងបង្ហាញដូចខាងក្រោម



៤ ឬ ចុច "ស្វែងរកតាមរយៈប័ណ្ណសម្គាល់ខ្លួន"

៤.១ ជ្រើសរើសប្រភេទប័ណ្ណ

៤.២ បញ្ចូលលេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

៤.៣ ចុចលើប៊ូតុង "ស្វែងរក"






ប្រព័ន្ធបង្ហាញថា ប័ណ្ណសម្គាល់នេះចុះឈ្មោះរួចហើយ







៥ ករណីពុំមានក្នុងប្រព័ន្ធ សូមចុច "ចុះបញ្ជីសមាជិកថ្មី"




៥.១ សូមបំពេញព័ត៌មានរបស់កម្មករនិយោជិត និងភ្ជាប់ឯកសារ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន រួចចុចលើប៊ូតុង "បន្ទាប់"




- ៥.២ សមាជិកត្រូវបានដាក់ស្នើ រង់ចាំការពិនិត្យសំណើរ និងឯកភាព ពីមន្ត្រី ប.ស.ស.




- ៥.៣ បន្ទាប់ពីមន្ត្រី ប.ស.ស. បានឯកភាពលើសំណើរួចសមាជិកនោះ នឹងទទួលបាន លេខអត្តសញ្ញាណសមាជិក ប.ស.ស.




សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
របៀបចុះបញ្ជីសមាជិក ប.ស.ស.
តាមប្រព័ន្ធ Web Base Application

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# របៀបប្រកាសសមាជិក ប.ស.ស. និងការបង់ភាគទាន
# តាមប្រព័ន្ធចុះបញ្ជិកា Web Base Application




១. ចុច "ប្រកាសសមាជិកបង់ភាគទាន"
២. ចុច "ចុះបញ្ជី"




១. ជ្រើសរើស
១.១ បន្ថែមសមាជិក
១.២ ទាញទិន្នន័យពីខែចាស់
១.៣ បញ្ចូលឯកសារ
២. កាលបរិច្ឆេទប្រកាសសមាជិក
៣. បញ្ចូល (Excel)
៤. បន្ទាប់
៥. បញ្ជាក់

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
របៀបប្រកាសសមាជិក ប.ស.ស.
និងការបង់ភាគទាន
តាមប្រព័ន្ធ Web Base Application



# របៀបប្រកាសសមាជិក ប.ស.ស. និងការបង់ភាគទាន
# តាមប្រព័ន្ធចុះបញ្ជិកា Web Base Application (ត)







## វិក្កយបត្របង់ប្រាក់

| ល.រ | ប្រភេទ | | ចំនួនទឹកប្រាក់ | ប្រាក់សរុប (រៀល) |
|---|---|---|---|---|
| | | របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ | 5,678,182 | |
| 1 | ភាគទាន | របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព | 18,454,075 | 52,475,200 |
| | | របបសន្តិសុខសង្គមផ្នែកប្រាក់សោធន | 28,342,906 | |
| | | | ប្រាក់សរុបរួម (រៀល) | 52,475,200 |

១០

ប្រព័ន្ធបង្ហាញទឹកប្រាក់សរុប ដែលលោកអ្នកត្រូវបង់

**ជម្រើសការបង់ប្រាក់**

- ធនាគារកាណាឌីយ៉ា
- ធនាគារអេស៊ីលីដា
- ធនាគារ ABA

សូម "បញ្ចូលតារាងបើកប្រាក់បៀវត្ស"

បិទ

១១

សូមស្កេនដើម្បីបង់ប្រាក់







១២

បន្ទាប់ពីលោកអ្នកបានបង់ភាគទានរួចរាល់ សូមលោកអ្នករង់ចាំរយៈពេលមួយសប្តាហ៍ ដើម្បីឱ្យមន្ត្រី ប.ស.ស. ធ្វើការពិនិត្យ និងចេញវិក្កយបត្រជូន



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍

General Department of Information and Broadcasting

លេខ : ០៤៤ ព.ស-ស.ម

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

## លិខិតអនុញ្ញាត

**យោង ៖** -ប្រកាសលេខ ១០៨ ប្រក.ព.ម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងព័ត៌មាន

-លិខិតលេខ ៤១០/២២ .ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ

-លិខិតស្នើសុំប្តូរឈ្មោះ និងទីតាំង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម។

តាមសេចក្តីដូចមានចែងក្នុងយោងខាងលើ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ជ្រាបថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន អនុញ្ញាតឱ្យព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ប្តូរឈ្មោះមកជាព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. និងមានអាសយដ្ឋានទីស្នាក់ការថ្មីស្ថិតនៅផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បន្តលិខិតលេខ ៤១០/២២-ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ក្នុងដំណើរការផ្សព្វផ្សាយ ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាស របស់ក្រសួងព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ ករណីប្រព្រឹត្តល្មើស សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ០១ (មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ត្រូវស្នើសុំបន្តសុពលភាពដើម្បីធ្វើសកម្មភាពការងារលើវិស័យព័ត៌មាន និងសោតទស្សន៍ មុនផុតកំណត់រយៈពេល ៣០ (សាមសិប) ថ្ងៃ។

**អគ្គនាយក**

**ផុស_សុវណ្ណ**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- អគ្គស្នងការនគរបាលជាតិ
- និយ័តករទូរគមនាគមន៍កម្ពុជា
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរព័ត៌មានរាជធានីភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ឯកសារ កាលប្បវត្តិ